# សេចក្តីថ្លែងរបស់បេក្ខជន

**John Collins**
**សហរដ្ឋអាមេរិក**

បច្ចុប្បន្ន ខ្ញុំបម្រើការងារជាប្រធានក្រុមប្រឹក្សាភិបាលរបស់សាលាអន្តរជាតិភ្នំពេញ។
ខ្ញុំស្ថិតក្នុងក្រុមប្រឹក្សាភិបាល អស់រយៈពេល ២ ឆ្នាំកន្លះមកហើយ
ហើយក៏ធ្លាប់កាន់តួនាទីជាអនុប្រធានផងដែរ។ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល
យើងបានពង្រឹងសាលាអន្តរជាតិភ្នំពេញតាមរយៈការគាំទ្រដំណើរការផ្លាស់ប្តូរថ្នាក់ដឹកនាំសាលារៀន
អភិវឌ្ឍផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំថ្មី បង្កើនកិច្ចការសប្បុរសធម៌ និងបង្កើតកម្មវិធីអាហារូបករណ៍ថ្មី។
ខ្ញុំជាជនជាតិអាមេរិក និងមានកូន ៣ នាក់រៀននៅសាលាអន្តរជាតិភ្នំពេញ នៅថ្នាក់ទី ៤ ថ្នាក់ទី ៧ និងថ្នាក់ទី ១១ ។

ខ្ញុំមានសញ្ញាប័ត្របណ្ឌិតផ្នែកទ្រឹស្តី និងគោលនយោបាយអប់រំ និងមានបទពិសោធន៍ជាង ១០ ឆ្នាំ
ធ្វើការលើការពង្រឹងប្រព័ន្ធអប់រំសម្រាប់កុមារនៅប្រទេសម៉ាឡាវី សាធារណរដ្ឋប្រជាមានិតកុងហ្គោ អាហ្គានីស្ថាន
និងប្រទេសកម្ពុជា។ ខ្ញុំយល់អំពីអាទិភាពផ្នែកច្បាប់ និងអាទិភាពផ្នែកស្ថាប័ន
នាពេលបច្ចុប្បន្នរបស់សាលាអន្តរជាតិភ្នំពេញ
ហើយអាចគាំទ្រដល់ដំណើរការចាំបាច់ដើម្បីបន្ស៊ីរចនាសម្ព័ន្ធស្ថាប័នផ្នែកច្បាប់របស់សាលារៀន
ជាមួយក្របខ័ណ្ឌការងារគោលនយោបាយបច្ចុប្បន្នភាព។

សម្រាប់ចក្ខុវិស័យទៅអនាគត សាលាអន្តរជាតិភ្នំពេញក៏ចាំបាច់ត្រូវអនុវត្តផែនការយុទ្ធសាស្ត្រដ៏រឹងមាំ
ដែលក្នុងនោះរួមមានការពង្រឹងការប្តេជ្ញាចិត្តរបស់យើង ចំពោះការគាំទ្រការរៀនសូត្រ កិច្ចការសប្បុរសធម៌
អាហារូបករណ៍ និងបង្ហើយរចនាសម្ព័ន្ធផ្នែកច្បាប់ និងផ្នែកអភិបាលកិច្ចដែលមានលក្ខណៈឆ្លើយតបឱ្យចប់ជាស្ថាពរ
ដើម្បីជំរុញឱ្យសាលាអន្តរជាតិភ្នំពេញមានភាពឆ្លើយតបចំពោះសេចក្តីត្រូវការនាពេលបច្ចុប្បន្ន និងអនាគតបាន។
ប្រសិនបើជាប់ឆ្នោត ខ្ញុំរំពឹងថានឹងអាចជួយសាលាអន្តរជាតិភ្នំពេញ ក្នុងការប្រែក្លាយផែនការយុទ្ធសាស្ត្រថ្មីរបស់យើង
ឱ្យទៅជាសកម្មភាពជាក់ស្តែង ដោយមានកញ្ចប់ថវិកាដែលបានអនុម័ត ដើម្បីធានាឱ្យបានថា
ផ្នែករដ្ឋបាលសាលាអាចសម្រេចបានគោលបំណងប្រកបដោយមហិច្ឆតា ប៉ុន្តែមានលក្ខណៈជាក់ស្តែងរបស់ខ្លួន
ក្នុងការពង្រឹងបទពិសោធន៍របស់សិស្សានុសិស្ស បុគ្គលិកសិក្សា
និងសហគមន៍សាលាអន្តរជាតិភ្នំពេញរបស់យើងថែមទៀត។

**Narendra Kumar**
**ឥណ្ឌា**

ខ្ញុំសូមផ្តល់ជំនាញឯកទេស
និងបទពិសោធន៍របស់ខ្ញុំជូនដល់ក្រុមប្រឹក្សាភិបាលរបស់សាលាអន្តរជាតិភ្នំពេញ។
ខ្ញុំមានចំណាប់អារម្មណ៍ចង់ជួយក្រុមប្រឹក្សាភិបាល
និងរដ្ឋបាលសាលាឱ្យអាចគ្រប់គ្រងលើចំណុចខ្លាំងនាពេលបច្ចុប្បន្ន និងការពង្រីកសាលារៀននាពេលអនាគត
ព្រមទាំងរក្សា និងអភិវឌ្ឍកេរ្តិ៍ឈ្មោះរបស់សាលាអន្តរជាតិភ្នំពេញក្នុងនាមជាសាលាជាប់លំដាប់លេខ

១ក្នុងប្រទេសកម្ពុជា។ ខ្ញុំអាចចែករំលែកបទពិសោធន៍របស់ខ្ញុំក្នុងវិស័យនេះ ដើម្បីជួយសម្រេចបានបេសកម្ម
និងចក្ខុវិស័យរបស់សាលា  និងការអភិវឌ្ឍរបស់សាលាក្នុងនាមជាមជ្ឈមណ្ឌលឧត្តមភាព។
ខ្ញុំបានចូលរួមក្នុងអនុគណៈកម្មាធិការផែនការយុទ្ធសាស្រ្ត ផ្នែកបរិស្ថាន និងសុខុមាលភាព
ហើយចង់បន្តចូលរួមចំណែកក្នុងសសរស្តម្ភទាំងអស់នេះ របស់ផែនការយុទ្ធសាស្រ្តសាលារៀន។

ដោយធ្លាប់បានរស់នៅក្នុងតំបន់អាមេរិក និងអាហ្វ្រិក នៅមុនពេលផ្លាស់មកក្នុងប្រទេសកម្ពុជា នៅឆ្នាំ ២០១១
ខ្ញុំគឺជាអ្នកតំណាងឧស្សាហកម្មថែទាំសុខភាពនៅតាមវេទិកាផ្សេងៗជាច្រើន ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។
ក្នុងនាមជាសមាជិកនៅក្នុងក្រុមផ្សេងៗជាច្រើនដូចជា Eurocham, CAMFEBA, ក្រុមប្រឹក្សាធុរៈកិច្ចថៃ
និងសមាគមឥណ្ឌានៅកម្ពុជា (អនុប្រធាន) ជាដើម
ខ្ញុំទទួលបានព័ត៌មានបច្ចុប្បន្នភាពស្ដីពីនិន្នាការថ្មីៗបំផុតរបស់អាជីវកម្ម និងវឌ្ឍនភាពផ្នែកសង្គមសេដ្ឋកិច្ចរបស់តំបន់។

ខ្ញុំមកពីប្រទេសឥណ្ឌា ហើយខ្ញុំមានកូនស្រីពីរនាក់ រៀននៅសាលាអន្តរជាតិភ្នំពេញ ក្នុងថ្នាក់ទី ១ និងថ្នាក់ទី ៨។
គ្រួសាររបស់យើង គឺជាផ្នែកមួយរបស់សហគមន៍សាលាអន្តរជាតិភ្នំពេញតាំងពីឆ្នាំ ២០១១ មក។
ខ្ញុំផ្តល់បទពិសោធន៍ផ្សេងៗជាច្រើនក្នុងការធ្វើផែនការយុទ្ធសាស្រ្ត ការអភិវឌ្ឍអាជីវកម្ម ការលក់
និងការធ្វើទីផ្សារអន្តរជាតិ ការអភិវឌ្ឍមនុស្ស និងការគ្រប់គ្រងទូទៅ។ ប្រសិនបើជាប់ឆ្នោត ខ្ញុំចង់យកសាវតារ
និងជំនាញរបស់ខ្ញុំទៅអនុវត្តដើម្បីជួយដល់សាលាអន្តរជាតិភ្នំពេញឱ្យរក្សាភាពប្រកួតប្រជែង
សម្រេចបានគោលដៅផ្នែកហិរញ្ញវត្ថុ និងផ្នែកយុទ្ធសាស្រ្ត និងបន្តគាំទ្រដល់សិស្សានុសិស្សរបស់យើង
ឱ្យមានលទ្ធភាពចូលទៅកាន់សាកលវិទ្យាល័យប្រសើរជាងគេបំផុត។

**Jenny Pearson**
**ចក្រភពអង់គ្លេស**
បច្ចុប្បន្នខ្ញុំបម្រើការជាអនុប្រធានក្រុមប្រឹក្សាភិបាល



ហើយធ្លាប់បានដឹកនាំគណៈកម្មាធិការផែនការយុទ្ធសាស្រ្តក្នុងនាមជាប្រធានគណៈកម្មាធិការនេះអស់រយៈពេលជាង ១ ឆ្នាំ។ ក្នុងឆ្នាំនេះ ក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន បានធ្វើការជាមួយគ្នាយ៉ាងល្អ ដើម្បីធានាឱ្យមានភាពរឹងមាំ
និងស្ថេរភាពជាបន្តរបស់សាលា ក្នុងអំឡុងរយៈពេលការផ្លាស់ប្តូរនាយកសាលា ហើយឥឡូវនេះ
យើងក៏កំពុងឆ្លងកាត់ស្ថានភាពមិនធ្លាប់កើតមានពីមុនមក ដែលទាមទារឱ្យសាលាត្រូវបង្រៀន និងរៀនតាមអនឡាញ។
ការចូលរួមរបស់ខ្ញុំជាមួយគណៈកម្មាធិការ និងសកម្មភាពនានារបស់ក្រុមប្រឹក្សាភិបាលក្នុងរយៈពេល ២ ឆ្នាំកន្លងមក
បានធ្វើឱ្យខ្ញុំយល់កាន់តែច្បាស់អំពីរបៀបដែលសាលាបំពេញមុខងារ និងអាទិភាពនាពេលបច្ចុប្បន្ន
និងនាពេលអនាគតរបស់សាលា។ ក្នុងនាមជាអ្នករស់នៅក្នុងប្រទេសកម្ពុជា អស់រយៈពេល ២៥ ឆ្នាំកន្លងមកនេះ
ខ្ញុំមានការយល់ដឹងយ៉ាងល្អអំពីវប្បធម៌កម្ពុជា និងបរិបទ ពាក់ព័ន្ធជាមួយការបំពេញមុខងាររបស់សាលា។
ខ្ញុំក៏មានបទពិសោធន៍ផ្នែកអភិបាលកិច្ចក្នុងស្ថាប័ននានាជាច្រើន និងជាអ្នកជំនាញឯកទេសផ្នែកការគ្រប់គ្រង
និងអភិវឌ្ឍសមត្ថភាពផងដែរ។

ដំណើរការនៃការធ្វើផែនការយុទ្ធសាស្រ្ត មានលក្ខណៈពិគ្រោះយោបល់ខ្ពស់ ដើម្បីកំណត់រកគោលដៅរបស់យើង
និងធ្វើផែនការដើម្បីនាំសាលាឈានឆ្ពោះទៅមុខ ក្នុងលក្ខណៈគួរជាទីរំភើបរីករាយ សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ

ក្នុងបរិបទនៃការប្រកួតប្រជែង ដែលរីកធំកាន់តែឆាប់រហ័ស ព្រមទាំងនិន្នាការដ៏រស់រវើក
នៅក្នុងសហគមន៍ជនបរទេស។ គោលដៅអាទិភាពដែលត្រូវបានកំណត់ឃើញ ក្នុងដំណើរការនេះមាន៖ ពង្រឹង
និងពង្រីកគន្លងអប់រំរបស់សាលាអន្តរជាតិភ្នំពេញ សម្រាប់សិស្សានុសិស្សដែលមានសេចក្តីត្រូវការចម្រុះគ្នា ពង្រីក
និងដាក់បញ្ចូលការប្តេជ្ញាចិត្តរបស់សាលាក្នុងកិច្ចការសប្បុរសធម៌ បរិស្ថាន និងសុខុមាលភាព
ពង្រឹងក្របខ័ណ្ឌការងារផ្នែកច្បាប់ និងអភិបាលកិច្ច និងពង្រីកការចូលរួមរបស់សាលា
និងសេវានានាជាមួយសហគមន៍។ ម្យ៉ាងវិញទៀត ជាការសំខាន់ខ្លាំងណាស់ដែលមូលដ្ឋានផ្នែកហិរញ្ញវត្ថុ
នៃប្រតិបត្តិការរបស់សាលាចាំបាច់ត្រូវតែមានភាពរឹងមាំ
ដើម្បីធ្វើឱ្យសាលានៅតែមានភាពនាំមុខគេខាងការផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ក្នុងប្រទេសកម្ពុជា។

ប្រសិនបើបានជាប់ឆ្នោត ខ្ញុំរំពឹងថានឹងបន្តផ្តល់ការគាំទ្រដល់សាលាក្នុងរយៈពេលពីរឆ្នាំខាងមុខ
ហើយជួយសាលាអន្តរជាតិភ្នំពេញឱ្យសម្រេចបានគោលដៅទាំងអស់នេះ
ព្រមទាំងបន្តទៅទទួលជោគជ័យកាន់តែធំធេងថែមទៀតក្នុងនាមជាសាលាអន្តរជាតិនាំមុខគេក្នុងប្រទេសកម្ពុជា។

**Tola Ponlu**
**កម្ពុជា**



ខ្ញុំជាអ្នកតស៊ូមតិសម្រាប់វិស័យអប់រំ និងជាអ្នកជឿជាក់ដ៏មុតមាំថា
ការអប់រំគឺជាមធ្យោបាយដ៏ប្រសើរបំផុតដើម្បីកាត់បន្ថយភាពក្រីក្រ។
ក្នុងនាមជាឪពុករបស់កូនបីនាក់ ខ្ញុំជឿជាក់ថា
ខ្ញុំអាចបន្តជាសមាជិកដ៏មានតម្លៃរបស់ក្រុមប្រឹក្សាភិបាលសាលាអន្តរជាតិភ្នំពេញ
ដោយខ្ញុំធ្លាប់បានបម្រើក្រុមប្រឹក្សាភិបាលនេះរយៈពេល ១ ឆ្នាំកន្លងមកហើយ។
ខ្ញុំជាជនជាតិកម្ពុជា ហើយខ្ញុំមានបណ្តាញយ៉ាងរឹងមាំ ទាំងនៅកម្រិតសាជីវកម្ម
និងកម្រិតរដ្ឋាភិបាល ដែលជាទូទៅនឹងអាចជួយខ្ញុំដើម្បីចូលរួមចំណែក ចំពោះជោគជ័យរបស់ក្រុមប្រឹក្សាភិបាល។

បទពិសោធន៍រយៈពេល ១៥ ឆ្នាំរបស់ខ្ញុំ ក្នុងពិភពសាជីវកម្ម ជាមួយតួនាទីជាន់ខ្ពស់នានា ក្នុងផ្នែកប្រាស្រ័យទាក់ទង
ទីផ្សារ ផែនការ ការគ្រប់គ្រងអ្នកពាក់ព័ន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុ
ច្បាស់ជានឹងមានសារៈប្រយោជន៍ជាខ្លាំងសម្រាប់ក្រុមប្រឹក្សាភិបាល ជាពិសេសដើម្បីជួយជាស្ពានភ្ជាប់
និងបង្កការចូលរួមជាមួយសហគមន៍កម្ពុជារបស់សាលាអន្តរជាតិភ្នំពេញ។
កម្រងជំនាញរបស់ខ្ញុំក្នុងវិស័យប្រាស្រ័យទាក់ទង ប្រាកដជាមានសារប្រយោជន៍
ចំពោះសកម្មភាពទូទៅរបស់ក្រុមប្រឹក្សាភិបាល
ហើយខ្ញុំបានចូលរួមចំណែករួចហើយនៅក្នុងអនុគណកម្មាធិការផែនការយុទ្ធសាស្ត្រ
ដើម្បីធ្វើការងារលើប្រធានបទស្តីពីកេរ្តិ៍ឈ្មោះ។

សាលាអន្តរជាតិភ្នំពេញ មានកេរ្តិ៍ឈ្មោះដ៏អស្ចារ្យ។ បទពិសោធន៍របស់ខ្ញុំក្នុងវិស័យការប្រាស្រ័យទាក់ទងផ្នែកស្ថាប័ន
នឹងអាចជួយដល់សាលាអន្តរជាតិភ្នំពេញឱ្យប្រាស្រ័យទាក់ទង ជាមួយអ្នកពាក់ព័ន្ធខាងក្នុង និងអ្នកពាក់ព័ន្ធខាងក្រៅ
ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រថ្មី ការអភិវឌ្ឍនាយកសាលា និងការធ្វើផែនការថវិកា។ ប្រសិនបើជាប់ឆ្នោត
ខ្ញុំរំពឹងថានឹងអាចជួយឱ្យក្រុមប្រឹក្សាភិបាលបន្តដោះស្រាយបញ្ហានានា
ដូចជាថាតើធ្វើយ៉ាងណាដើម្បីឱ្យសាលាអន្តរជាតិភ្នំពេញ
អាចដោះស្រាយលើបញ្ជីសិស្សរង់ចាំដ៏វែងរបស់ខ្លួនបានជាដើម។

**Clarisse Kehler Siebert**
**ស៊ុយអែត**



ក្នុងនាមជាទីប្រឹក្សាពិសេស (ផ្នែកច្បាប់) ជូនដល់ក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន ចាប់ពីខែសីហា ឆ្នាំ
២០១៩ មក ខ្ញុំគឺជាផ្នែកមួយនៃក្រុមការងារ ដែលបានកសាងការទុកចិត្ត ភាពជាសហភាតា
និងវិធីប្រកបដោយប្រសិទ្ធភាពក្នុងការធ្វើការជាមួយគ្នា
ដោយកាលពីដំបូងគឺយើងធ្វើការក្នុងពេលវេលាជាប្រក្រតី

ហើយថ្មីៗនេះយើងបានទទួលការពិសោធធ្វើការក្នុងពេលវេលានៃជំងឺ កូវីដ១៩ ដែលមិនធ្លាប់មានពីមុនមក។ ក្នុងនាមជាប្រធានគណៈកម្មាធិការ អភិបាលកិច្ច និងគោលនយោបាយរបស់សាលាអន្តរជាតិភ្នំពេញ ខ្ញុំបានចូលរួមចំណែកនៅក្នុងការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់ឡើងវិញសម្រាប់សាលាអន្តរជាតិភ្នំពេញ និងដឹកនាំការកែសម្រួលជាបន្តបន្ទាប់លើធម្មនុញ្ញរបស់សាលា ដើម្បីឱ្យអនុលោមតាមរចនាសម្ព័ន្ធផ្នែកច្បាប់ថ្មី។ ខ្ញុំចង់ឃើញគម្រោងទាំងអស់នេះ បន្តឈានឆ្ពោះទៅបញ្ចប់ឱ្យបានរួចរាល់ក្នុងឆ្នាំសិក្សា ២០២០-២០២១។ តាមរយៈការធ្វើការងាររួមជាមួយ សហការីនៅក្នុងក្រុមប្រឹក្សាភិបាល ដែលដាក់ពាក្យជាបេក្ខជនសម្រាប់ការបោះឆ្នោតឡើងវិញ ខ្ញុំមានក្តីប្រាថ្នាចង់រក្សាការងាររបស់យើងរួមជាមួយគ្នាជាបន្ត។ ខ្ញុំប្តេជ្ញាចិត្តចំពោះផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំថ្មី ដែលត្រូវបានអភិវឌ្ឍឡើងក្នុងរយៈពេល ២ ឆ្នាំកន្លងមក ដែលនឹងត្រូវបានបង្ហាញ នៅក្នុងកិច្ចប្រជុំទូទៅប្រចាំឆ្នាំក្នុងឆ្នាំនេះ។

ខ្ញុំជាជនជាតិ ស៊ុយអែត-កាណាដា និងមានកូនម្នាក់រៀនថ្នាក់ទី ២ នៅសាលាអន្តរជាតិភ្នំពេញ ហើយកូនទី ២ របស់ខ្ញុំនឹងចូលរៀននៅថ្នាក់មតេយ្យក្នុងឆ្នាំ ២០២០-២០២១។ គ្រួសាររបស់យើងបានមកប្រទេសកម្ពុជា កាលពីខែសីហាកន្លងទៅ តាមរយៈការចាត់តាំងភារកិច្ចការងាររបស់អង្គការសហប្រជាជាតិ។ ខ្ញុំជាមន្ត្រីគោលនយោបាយជាន់ខ្ពស់ ដែលបានសុំច្បាប់ឈប់សំរាកពីទីភ្នាក់ងារកិច្ចការពារបរិស្ថានស៊ុយអែត ហើយបច្ចុប្បន្នកំពុងផ្តល់ការគាំទ្រដល់ក្រសួងបរិស្ថានកម្ពុជា។ ក្នុងនាមជាមេធាវីដែលមានសញ្ញាបត្រ នៅក្នុងវិស័យច្បាប់ស៊ីវិល និងខំមិនទ្យ ព្រមទាំងមានបទពិសោធន៍ជាប្រធានក្រុមប្រឹក្សាភិបាលសាលាមិនរកប្រាក់ចំណេញ ក្នុងប្រទេសស៊ុយអែត ខ្ញុំបាននាំមកជាមួយនូវឧបករណ៍ដើម្បីគាំទ្រដំណើរការ ដើម្បីធ្វើឱ្យរចនាសម្ព័ន្ធផ្នែកច្បាប់របស់សាលាអន្តរជាតិភ្នំពេញ មានភាពសមស្របតាមគោលបំណងដែលចង់បាន។

ប្រសិនបើបានជាប់ឆ្នោត ខ្ញុំរំពឹងថានឹងផ្តល់ការគាំទ្រ ដល់ផែនការយុទ្ធសាស្ត្រថ្មីរបស់សាលាអន្តរជាតិភ្នំពេញ ដោយក្នុងនោះរួមមានទាំងការបង្កើយការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់របស់សាលារៀនឱ្យបានចប់រួចរាល់ ការអនុវត្តធម្មនុញ្ញកែសម្រួលឡើងវិញសម្រាប់សាលាអន្តរជាតិភ្នំពេញ ការច្របាច់បញ្ចូលគោលវិធីរបស់យើង ជាមួយកិច្ចការសប្បុរសធម៌ និងកម្មវិធីអាហារូបករណ៍ ព្រមទាំងការគាំទ្រក្នុងកិច្ចការរៀនសូត្រកាន់តែច្រើនឡើង សម្រាប់សេចក្តីត្រូវការផ្នែកការងាររៀនសូត្រចម្រុះគ្នានៃសហគមន៍របស់យើង។ នៅចំពោះមុខនេះ ការគាំទ្រដល់សិស្សានុសិស្ស និងផ្នែករដ្ឋបាលដែលរងផលប៉ះពាល់ពីការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ គឺជាចំណុចផ្តោតការយកចិត្តទុកដាក់ចម្បង។ សម្រាប់រយៈពេលវែង ការស្វែងរកដំណោះស្រាយអចិន្ត្រៃយ៍សម្រាប់ការផ្គត់ផ្គង់ថាមពលសូឡា របស់សាលាអន្តរជាតិភ្នំពេញគឺមានសារៈសំខាន់ណាស់ សម្រាប់ឱ្យសាលាអន្តរជាតិភ្នំពេញក្លាយជាសាលាមានលក្ខណៈអំណោយផលដល់បរិស្ថាន។

**Keng Somarith**

**កម្ពុជា**



ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន ហើយបានបំពេញតួនាទីនេះតាំងពីឆ្នាំ ២០១៩ មក ខ្ញុំបានឃើញក្រុមមនុស្សដ៏ពូកែ ដែលបានបំពេញតួនាទីរបស់ខ្លួនយ៉ាងឧស្សាហ៍ព្យាយាម និងប្រកបដោយក្តីគោរព ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលរបស់សាលាអន្តរជាតិភ្នំពេញ។ ខ្ញុំបានឃើញមានវឌ្ឍនភាពច្រើន ក្នុងរយៈពេលត្រឹមតែ ១ ឆ្នាំប៉ុណ្ណោះ ដូចជាការបកស្រាយបញ្ជាក់ច្បាស់អំពីគោលដៅរបស់ក្រុមប្រឹក្សាភិបាល ការកំណត់ផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ការបកស្រាយបញ្ជាក់អំពីស្ថានភាពផ្នែកច្បាប់របស់សាលាអន្តរជាតិភ្នំពេញ និងការអភិវឌ្ឍវិសោធនកម្មធម្មនុញ្ញរបស់សាលាអន្តរជាតិភ្នំពេញ។ ខ្ញុំមានមោទនភាព និងមានកិត្តិយស

ដោយបានធ្វើការជាមួយសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់
ហើយខ្ញុំបានបម្រើការងារនៅក្នុងអនុគណៈកម្មាធិការអភិបាលកិច្ច និងដឹកនាំការធ្វើផែនការយុទ្ធសាស្ត្រ
និងគណៈកម្មាធិការអភិបាលកិច្ច និងគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធជាមួយ
ការពិនិត្យឡើងវិញលើភាពស្របច្បាប់ផ្នែកស្ថាប័ន របស់សាលាអន្តរជាតិភ្នំពេញ។

ខ្ញុំជាចៅក្រមម្នាក់ ហើយខ្ញុំធ្លាប់បានធ្វើការនៅក្នុងវិស័យច្បាប់ អស់រយៈពេល ៩ ឆ្នាំមកហើយ។
ខ្ញុំក៏ជានាយកសាលាភូមិន្ទចៅក្រម ដោយក្នុងនោះ ខ្ញុំទទួលខុសត្រូវក្នុងការតាក់តែងកម្មវិធីបណ្ដុះបណ្ដាល
និងធានាប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាល សម្រាប់អនាគតចៅក្រម និងព្រះរាជអាជ្ញាសម្រាប់ប្រព័ន្ធតុលាការកម្ពុជា។
ខ្ញុំជាជនជាតិកម្ពុជា ហើយមានសញ្ញាប័ត្រអនុបណ្ឌិត មកពីសាកលវិទ្យាល័យ Northeastern University School of Law សហរដ្ឋអាមេរិក។ ជំនាញឯកទេសរបស់ខ្ញុំលើវិស័យផ្នែកច្បាប់កម្ពុជា និងបរិស្ថាននិយ័តកម្មកម្ពុជា
ផ្ដល់អត្ថប្រយោជន៍ដល់ក្រុមប្រឹក្សាភិបាលសាលាអន្តរជាតិភ្នំពេញ
ស្របពេលដែលសាលាត្រូវធ្វើការជាមួយផ្នែករដ្ឋបាល ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រថ្មី
និងបន្តពង្រឹងស្ថានភាពផ្នែកច្បាប់របស់សាលាអន្តរជាតិភ្នំពេញក្នុងប្រទេសកម្ពុជា។

ដោយហេតុថាសាលាអន្តរជាតិភ្នំពេញ ឈរជាសាលានាំមុខគេមួយ ក្នុងប្រទេសកម្ពុជា និងក្នុងតំបន់
សម្រាប់ពេលទៅអនាគតទៀត បទពិសោធន៍ផ្នែកច្បាប់របស់ខ្ញុំនឹងផ្ដល់អត្ថប្រយោជន៍ដ៏ល្អសម្រាប់សាលា។
ប្រសិនបើបានជាប់ឆ្នោត ខ្ញុំនឹងបន្តបំពេញតួនាទីជាមួយសមាជិកក្រុម ដែលនឹងចែករំលែកចក្ខុវិស័យ និងគោលដៅរួមគ្នា
នៅពេលដែលយើងធ្វើការសម្រេចចិត្តពាក់ព័ន្ធជាមួយ ការរៀនសូត្រ ហិរញ្ញវត្ថុ សហគមន៍ គ្រឹះស្ថាន
និងធនធាននានា។